# ឯកឧត្តម ចម ប្រសិទ្ធ និងលោកជំទាវ ដង្ហែទៀនព្រះវស្សា
# ទៅកាន់វត្តមួយចំនួននៅទីរួមខេត្តសៀមរាប




ដោយមាននិស្ស័យ និងមានជំនឿយ៉ាងមុតមាំទៅលើគន្លងនៃព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ នៅឆ្នាំនេះ ក៏ដូចជានៅបណ្តាឆ្នាំមុនៗ ក្នុងកាលវេលានៃពិធីសិតទៀនព្រះវស្សាជិតឈានចូលមកដល់ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោកជំទាវ **ទេព បុប្ផាប្រសិទ្ធ** ព្រមទាំង បុត្រ ធីតា រួមនិងមន្ត្រីរាជការ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ព្រមទាំងអាជ្ញាធរ និងប្រជាពលរដ្ឋនៅខេត្តសៀមរាប នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១០ បានមូលមតិគ្នាជាឯកច្ឆ័ន្ទ ផ្តួចផ្តើមពិធីដង្ហែទៀនព្រះវស្សា ដើម្បីវេរប្រគេនដល់ព្រះសង្ឃដែលគង់នៅវត្តចំនួន០៧ ស្ថិតនៅក្រុងសៀមរាបរួមមាន: **វត្តពោធិបន្ទាយជ័យ-វត្តអធ្វារ-វត្តមុនីសុវណ្ណ-វត្តស្វាយ-វត្តកេសរារ៉ាម-វត្តព្រះឥន្ទកោ សីយ៍-និងវត្តព្រះឥន្ទកោសា** ដោយវត្តនីមួយៗទទួល បានទៀនព្រះវស្សា ចំនួន០២គូ-អង្ករ១០០គីឡូក្រាម-មី០២កេស-ទឹកត្រី០២យួរ-ទឹកស៊ីអ៊ីវ០២យួរ-ប៊ីចេង២៥គ.ក្រ-ទឹកក្រូច០២កេស-ទឹកដោះគោ១០កំប៉ុង-ស្ករស០៥គ.ក្រ-ទឹកសុទ្ធ ០៥ យួរ-ប្រេងកាត៣០លីត្រ និងបច្ច័យ៥០ម៉ឺនរៀល ព្រមទាំងប្រគេនទ័យវត្ថុ ស្បង់ចីវរ និងថវិការដល់ព្រះសង្ឃគ្រប់អង្គ ដែលគង់នៅក្នុងវត្តទាំង ០៧ខាង លើផងដែរ ។ ដោយឡែកអាស្រមព្រះនាងចេក-ព្រះនាងចម ដែលប្រជាពលរដ្ឋនៅ ខេត្តសៀមរាប ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេសតែងមានជំនឿគោរពបូជានោះ ក៏ត្រូវបានប្រារព្ធធ្វើពិធីដង្ហែទៀន ព្រះវស្សាប្រទក្សិណជុំវិញអាស្រម ចំនួន០៣ជុំ តាមគន្លងប្រពៃណីព្រះពុទ្ធសាសនា ដោយមាននិមន្តព្រះសង្ឃចំនួន០៧ អង្គសូត្រមន្តឧទ្ទិសកុសលផលបុណ្យ ដែលកើតឡើងពីការដង្ហែទៀនព្រះវស្សានេះ ជូនដល់ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និង លោកជំទាវ **ទេព បុប្ផាប្រសិទ្ធ** ព្រមទាំងក្រុមគ្រួសារ និងមន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក៏ដូចជាអាជ្ញាធរនិងប្រជាពលរដ្ឋនៅខេត្តសៀមរាប សូមទទួលបាននូវសុខភាពបរិបូរណ៍ ប្រាជ្ញាវៀងវៃ ពិសេសសម្រេចបានជោគជ័យថ្មីៗថែមទៀត ក្នុងភារកិច្ច បំរើជាតិ មាតុភូមិ ។

គួរបញ្ជាក់ថា៖ តាមពុទ្ធានុញ្ញាត ទៀនចំណាំព្រះវស្សាត្រូវបានអុចបំភ្លឺរយៈពេល០៣ខែ ចាប់ពីថ្ងៃ០១ រោជ ខែអាសាឍ ដល់ថ្ងៃ១៥កើត ខែអស្សុជ ដែលជារយៈពេល នៃការគង់ចាំព្រះវស្សារបស់ព្រះសង្ឃ ក្នុងព្រះពុទ្ធសាសនា ។ ទៀនព្រះវស្សាមានន័យថា៖ ការដុតបំភ្លឺចំពោះព្រះពុទ្ធប្បដិមា និងការស្វាធ្យាយ រៀនធម៌វិន័យរបស់ព្រះសង្ឃ ហើយក៏ជាប្រទីពសំរាប់បំភ្លឺស្វែងរកសេចក្តីសុខ ទៅអនាគតជាតិ ហើយការទទួលអានិសង្សមកវិញនោះ គឺមាននេត្រាភ្លឺច្បាស់ និងបញ្ញាភ្លឺស្វាង ដូចជាការដុតបំភ្លឺទៀនព្រះវស្សាយ៉ាងដូច្នេះឯង ហើយក៏ជាផលអានិសង្ស សំរាប់ឧទ្ទិសកុសល្យផលបុណ្យ ដល់បុព្វការីជន មានជីដូន ជីតា មាតា បិតា ញាតិការទាំងប្រាំពីរសន្តាន ដែលទទួលមរណៈកាលទៅកាន់លោកខាងមុខ សូមបានទៅកាន់សុគតិភព កុំបីឃ្លាងឃ្លាតឡើយ ។